# សុន្ទរកថាបើកកិច្ចប្រជុំ គ.ជ.អ.ប លើកទី៦
# ថ្លែងដោយឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
# និងជាប្រធាន គ.ជ.អ.ប

ទីស្តីការក្រសួងមហាផ្ទៃ ថ្ងៃទី២៦ ខែមករា ឆ្នាំ២០១២

- **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ឯកឧត្តមទេសរដ្ឋមន្ត្រី ឯកឧត្តម លោកជំទាវរដ្ឋមន្ត្រី រដ្ឋលេខាធិការ សមាជិក សមាជិកានៃ គ.ជ.អ.ប**
- **ឯកឧត្តមប្រធានក្រុមប្រឹក្សា និងអភិបាលរាជធានី ខេត្ត**
- **ឯកឧត្តម លោកជំទាវ លោកស្រី អស់លោក**

ថ្ងៃនេះ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ បានរៀបចំនូវកិច្ចប្រជុំលើកទី៦ បន្ទាប់ពីមានការខកខានរៀបចំនូវកិច្ចប្រជុំរបស់ខ្លួនក្នុងរយៈពេលមួយឆ្នាំនៃឆ្នាំ២០១១កន្លងមកនេះ ដោយសារមូលហេតុសំខាន់នៃភាពមមារញឹកខ្លាំងក្នុងការរៀបចំកម្មវិធី យន្តការ និងការសម្របសម្រួលជាមួយដៃគូពាក់ព័ន្ធនានា ដើម្បីជានាបាននូវការចាប់ផ្តើមអនុវត្តកម្មវិធីជាតិរយៈពេល ១០ឆ្នាំសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ នៅក្នុងដំណាក់កាលអន្តរកាលនៃឆ្នាំ ២០១១។

ក្នុងឱកាសដ៏ថ្លៃថ្លានេះ ក្នុងនាម គ.ជ.អ.ប និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំមានបីតិសោមនស្សរីករាយយ៉ាងក្រៃលែង សូមថ្លែងអំណរគុណ និងសូមស្វាគមន៍យ៉ាងកក់ក្តៅចំពោះឯកឧត្តម លោកជំទាវ សមាជិក សមាជិកា គ.ជ.អ.ប និងឯកឧត្តម លោកជំទាវ លោកស្រី អស់លោកទាំងអស់ ដែលមានវត្តមានក្នុងកិច្ចប្រជុំដ៏មានសារៈសំខាន់នាព្រឹកនេះ។

**ឯកឧត្តម លោកជំទាវ លោកស្រី អស់លោក!**

ខ្ញុំសូមអនុញ្ញាតធ្វើការវាយតម្លៃខ្ពស់ចំពោះការប្តេជ្ញាចិត្ត និងការចូលរួមចំណែក និងផ្តល់កិច្ចសហការយ៉ាងសកម្មរបស់ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ក្នុងការគាំទ្រដល់កិច្ចដំណើរការកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ ផ្តើមចេញពីកិច្ចសហការ ការចូលរួម និងការតាំងចិត្តយ៉ាងខ្លាំងក្លារបស់ឯកឧត្តម លោកជំទាវ លោកស្រី អស់លោក និងអ្នកពាក់ព័ន្ធនានាបានធ្វើឱ្យកិច្ចដំណើរការអនុវត្តគោលនយោបាយកំណែទម្រង់របស់យើង ប្រព្រឹត្តទៅស្របតាមឆន្ទៈនយោបាយរបស់រាជរដ្ឋាភិបាល ស្របតាមគោលការណ៍ដែលបានកំណត់ដោយច្បាប់រៀបចំអង្គការ និងស្របតាមវិធីសាស្ត្រជាយុទ្ធសាស្ត្រ ដែលបានឯកភាពគ្នានៅក្នុងកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែប ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

ក្រោមក្របខ័ណ្ឌនៃកិច្ចដំណើរការកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិ នៅក្នុងឆ្នាំ២០១១នេះ មានសមិទ្ធផលសំខាន់ៗជាច្រើនដែលសម្រេចបាន ក្នុងនោះរួមមានៈ សមិទ្ធផលពាក់ព័ន្ធនឹងការអភិវឌ្ឍគោលនយោបាយ ការ កែសម្រួលឡើងវិញនូវរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងនានារបស់ស្ថាប័ននៃរដ្ឋបាលថ្នាក់ក្រោមជាតិ ការរៀបចំ និងអនុវត្តកម្មវិធី ផែនការសកម្មភាព និងថវិកាសម្រាប់គាំទ្រដល់ប្រតិបត្តិការ ការអភិវឌ្ឍសមត្ថភាពស្ថាប័ន និងសមត្ថភាពបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ ការកៀរគរការបន្តគាំទ្រ និងការចូលរួមចំណែកពីដៃគូអភិវឌ្ឍន៍ អង្គការសង្គម ស៊ីវិល និងអ្នកពាក់ព័ន្ធ ព្រមទាំងការសម្របសម្រួល និងការធ្វើ ឲ្យមានសង្គតិភាពរវាងកិច្ចដំណើរការកំណែទម្រង់លើវិស័យសំខាន់ៗ ព្រមទាំង កម្មវិធី និងគម្រោងអភិវឌ្ឍន៍នានា ជាមួយនឹងកិច្ចដំណើរការនៃកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

ជារួម យើងអាចវាយតម្លៃបានថា ការចាប់ផ្តើមអនុវត្តនូវកិច្ចដំណើរការកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ក្នុងរបត់ថ្មី នៃក្របខ័ណ្ឌកម្មវិធីជាតិនៅក្នុងឆ្នាំ២០១១នេះ គឺជាការចាប់ផ្តើមដ៏ត្រឹមត្រូវតាមគោលនយោបាយ យុទ្ធសាស្ត្រ និងគោលការណ៍នានាដែលបានកំណត់នៅក្នុងក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ច្បាប់រៀបចំអង្គការ និងកម្មវិធីជាតិរយៈពេល១០ឆ្នាំសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ នេះជាសមិទ្ធផលថ្មីមួយទៀតរបស់រាជរដ្ឋាភិបាលក្នុងវិស័យកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ហើយក៏ជាបទពិសោធន៍ និងមេរៀនដ៏មានសារៈសំខាន់ សម្រាប់ធ្វើជាមូលដ្ឋានក្នុងការកែលំអការអនុវត្តកិច្ចដំណើរការនៃកំណែទម្រង់នេះនៅក្នុងឆ្នាំ២០១២ និងឆ្នាំបន្តបន្ទាប់ទៅមុខទៀត។ លេខាធិការដ្ឋាន គ.ជ.អ.ប នឹងរាយការណ៍ជូនអង្គប្រជុំរបស់យើងនាពេលបន្តិចទៀតនេះ អំពីវឌ្ឍនភាពនៃកិច្ចដំណើរការនៃកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិដែលសម្រេចបាននៅក្នុងឆ្នាំ២០១១។

ទន្ទឹមនឹងសម្រេចបាននូវសមិទ្ធផលគួរជាទីមោទនៈ ក៏មានបញ្ហាប្រឈមជាច្រើន ដែលត្រូវផ្តោតការយកចិត្តទុកដាក់ដោះស្រាយទាំងក្នុងក្របខ័ណ្ឌនៃការសម្រេចចិត្តខាងនយោបាយ និងទាំងក្នុងផ្នែកបច្ចេកទេស ដើម្បីកែលំអប្រសិទ្ធភាពក្នុងការបន្តកិច្ចដំណើរការកំណែទម្រង់ដ៏មានសារៈសំខាន់របស់យើងនៅក្នុងបណ្តាឆ្នាំខាងមុខៗតទៅទៀត និងដើម្បីធានាដល់ការសម្រេចបាននូវគោលដៅរយៈពេលវែងរបស់យើង ដែលបានកំណត់នៅក្នុងច្បាប់រៀបចំអង្គការ និងកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ ក្នុងឱកាសនេះ ខ្ញុំសូមធ្វើការគូសបញ្ជាក់ជូនអង្គប្រជុំនូវបញ្ហាប្រឈមផ្នែកនយោបាយជាគន្លឹះមួយចំនួនដូចខាងក្រោមៈ

**ទីមួយៈអំពីការរៀបចំប្រព័ន្ធផ្ទេរហិរញ្ញប្បទានដល់រដ្ឋបាលថ្នាក់ក្រុង ស្រុក**

យោងតាមស្មារតីនៃច្បាប់រៀបចំអង្គការ ច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ រដ្ឋបាលថ្នាក់ក្រុង ស្រុក ត្រូវបានទទួលស្គាល់ និងកំណត់ថាជាប្រភេទរដ្ឋបាលថ្នាក់មូលដ្ឋានដែលមាន

តួនាទីដ៏សំខាន់ក្នុងការចូលរួមចំណែកប្រកបដោយប្រសិទ្ធភាពក្នុងកិច្ចអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន និងការគាំទ្រផ្នែកបច្ចេកទេសដល់រដ្ឋបាលឃុំ សង្កាត់។ ឈរលើស្មារតីនេះ ផែនការអនុវត្តរយៈពេលបីឆ្នាំដំបូង (២០១១-២០១៣)នៃកម្មវិធីជាតិ ដែលយើងហៅកាត់ថា **ផអ៣** បានផ្តោតការយកចិត្តទុកដាក់ជាចម្បងទៅលើការពង្រឹងដល់ការរៀបចំឡើងវិញនូវរចនាសម្ព័ន្ធ និងប្រព័ន្ធអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យ ព្រមទាំងការអភិវឌ្ឍសមត្ថភាពបុគ្គលិក និងសមត្ថភាពស្ថាប័ននៃរដ្ឋបាលថ្នាក់ក្រុង ស្រុក។

មកដល់ពេលនេះ ក្រុមប្រឹក្សាក្រុង ស្រុក ត្រូវបានបង្កើត និងចូលកាន់តំណែងអស់រយៈពេលជាង ២ឆ្នាំកន្លងមកហើយ។ ស្របជាមួយគ្នានេះដែររចនាសម្ព័ន្ធគ្រប់គ្រងក្រុង ស្រុកក៏ត្រូវបានកែសម្រួលឡើងវិញ ដើម្បីឆ្លើយតបទៅនឹងតម្រូវការនៃការគ្រប់គ្រងតាមគោលការណ៍អភិបាលកិច្ចតាមបែបប្រជាធិបតេយ្យ និងលើកកម្ពស់ប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ។ ជាមួយគ្នានេះដែរ មន្រ្តីរាប់ពាន់នាក់ក៏ត្រូវបានធ្វើសមាហរណកម្មទៅក្នុងរចនាសម្ព័ន្ធដែលបានកែសម្រួលជាថ្មីនេះផងដែរ។ លើសពីនេះទៀត ផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ក្រុង ស្រុកទាំងអស់ ក៏ត្រូវបានកសាងឡើងតាមវិធីសាស្រ្តប្រកបដោយការចូលរួម និងពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋ ព្រមទាំងត្រូវបានអនុម័តរួចរាល់ដោយក្រុមប្រឹក្សារបស់ខ្លួន ក្នុងន័យឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ និងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាននៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

ទោះជាយ៉ាងនេះក្តី ក្នុងស្ថានភាពបច្ចុប្បន្ននេះ រដ្ឋបាលថ្នាក់នេះ នៅពុំទាន់មានលទ្ធភាពក្នុងការចាប់ផ្តើមអនុវត្តផែនការអភិវឌ្ឍន៍របស់ខ្លួន ក្នុងន័យមានស្វ័យភាពធនធាន និងការធ្វើសេចក្តីសម្រេចចិត្តរបស់ខ្លួនឡើយ ដោយសារយើងពុំទាន់រៀបចំបាននូវយន្តការផ្ទេរមូលនិធិ និងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសម្រាប់រដ្ឋបាលថ្នាក់ក្រុង ស្រុកដែលមានលក្ខណៈអាចធ្វើឲ្យក្រុង ស្រុកធ្វើការព្យាករណ៍បានជាមុននៅឡើយ។ ការយឺតយ៉ាវនៃការរៀបចំ និងដាក់ឲ្យអនុវត្តនូវប្រព័ន្ធ និងយន្តការដ៏មានសារៈសំខាន់នេះ កំពុងមានផលប៉ះពាល់ផ្នែកនយោបាយគួរឲ្យព្រួយបារម្ភ។ ការគ្មានធនធានសម្រាប់ការឆ្លើយតបក្នុង កម្រិតណាមួយទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ និងក្រុមប្រឹក្សាឃុំ សង្កាត់ ដែលខ្លួនត្រូវមាន គណនេយ្យភាពជាបឋម នឹងធ្វើឲ្យក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់នេះពុំអាចពង្រឹងបាននូវការទទួលខុសត្រូវក្នុងការអនុវត្តអាណត្តិទូទៅរបស់ខ្លួន ដែលបានកំណត់ក្នុងច្បាប់រៀបចំអង្គការ ព្រមទាំងធ្វើឲ្យបាត់បង់ជំនឿពីប្រជាពលរដ្ឋ និងក្រុមប្រឹក្សាឃុំ សង្កាត់ និងជះឥទ្ធិពលជាអវិជ្ជមានលើកិច្ចដំណើរការកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិទាំងមូល។

អាស្រ័យហេតុនេះ ក្នុងកិច្ចប្រជុំរបស់យើងនាព្រឹកនេះ យើងនឹងធ្វើការពិភាក្សា ពិគ្រោះយោបល់ និងឯកភាពគ្នាលើសេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃមូលនិធិក្រុង ស្រុក ដើម្បីដាក់ជូនរាជរដ្ឋាភិបាលពិនិត្យ និងអនុម័តក្នុងពេលឆាប់ៗខាងមុខនេះ។

ពាក់ព័ន្ធនឹងកិច្ចការនេះ ខ្ញុំសូមគូស បញ្ជាក់ថាអនុក្រឹត្យនេះ ជាលិខិតបទដ្ឋានគតិយុត្តដ៏មានសារៈសំខាន់មួយសម្រាប់ធានាដល់ការផ្តល់ធនធានគ្មានភ្ជាប់ល័ក្ខខ័ណ្ឌដល់រដ្ឋបាលក្រុង ស្រុក សម្រាប់កិច្ចអភិវឌ្ឍន៍មូលដ្ឋានក្រោមស្វ័យភាពនៃការសម្រេចចិត្តរបស់ខ្លួន។ ក្រៅពីនេះ ដើម្បីធានាដល់ការគ្រប់

គ្រង ចាត់ចែង និងប្រើប្រាស់ធនធានដែលបានផ្តល់ឲ្យទាំងនេះ ប្រកបដោយប្រសិទ្ធភាព តម្លាភាព និង គណនេយ្យភាពក្នុងការឆ្លើយតបទៅនឹងតម្រូវការអាទិភាពរបស់ប្រជាពលរដ្ឋ តម្រូវឲ្យដាក់ចេញនូវលិខិត បទដ្ឋានគតិយុត្ត និងសេចក្តីណែនាំបច្ចេកទេសជាច្រើនផ្សេងទៀត។ លិខិតបទដ្ឋានគតិយុត្ត និងសេចក្តី ណែនាំបច្ចេកទេសទាំងអស់នេះ ក៏ត្រូវចាំបាច់រៀបចំ និងដាក់ឲ្យប្រើប្រាស់នៅក្នុងត្រីមាសទី១នៃឆ្នាំ ២០១២នេះ ដើម្បីធានាដល់ការអភិវឌ្ឍសមត្ថភាពសម្រាប់ការអនុវត្តប្រព័ន្ធនេះឲ្យបានសមស្រប និងទាន់ ពេលវេលាផងដែរ។

ក្នុងករណីដែលលិខិតបទដ្ឋានគតិយុត្ត និងសេចក្តីណែនាំបច្ចេកទេសទាំងនេះ មិនត្រូវបានរៀបចំ និងដាក់ចេញឲ្យប្រើប្រាស់បានទាន់ពេលវេលាដូចបានកំណត់នេះទេ នោះវានឹងមានផលប៉ះពាល់មិនត្រឹម តែទៅលើការអនុវត្តនៅក្នុងឆ្នាំ២០១២នេះឡើយ ប៉ុន្តែវាថែមទាំងមានផលប៉ះពាល់ដល់ការអនុវត្តនៅក្នុង ឆ្នាំ២០១៣ផងដែរ អាស្រ័យដោយហេតុថា វដ្តនៃការរៀបចំថវិកាសម្រាប់ឆ្នាំ២០១៣ត្រូវចាប់ផ្តើមពីខែមិនា នៃឆ្នាំ២០១២។

### ទីពីរៈការផ្ទេរមុខងារ និងធនធានទៅឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិ

កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ គឺមានការពាក់ព័ន្ធចាំបាច់ទៅនឹងការផ្ទេរ មុខងារ និង ធនធានទៅឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។ ផ្ទុយមកវិញ បើគ្មានការផ្ទេរនូវមុខងារ និងធនធានទៅ ឲ្យរដ្ឋបាល ថ្នាក់ក្រោមជាតិ គឺគ្មានកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនោះឡើយ។ ការផ្ទេរមុខងារ និងធនធាន ឲ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិ គឺ ជាការបង្វិតសេវាឲ្យទៅកៀកជិតប្រជាពលរដ្ឋ មានតម្លាភាព និងមាន គណនេយ្យភាពចំពោះប្រជាពលរដ្ឋ ព្រមទាំងបង្កើននូវភាពជាម្ចាស់របស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលជា អ្នកជាប់ឆ្នោត និងការចូលរួមរបស់ប្រជាពលរដ្ឋ ដែលជាការរួមចំណែកដ៏មានសារសំខាន់សម្រាប់កិច្ចអភិវឌ្ឍ មូលដ្ឋាន ដែល ទាំងនេះគឺជាគោលបំណងដ៏សំខាន់មួយនៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ ក្រោមជាតិតាមរយៈកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។ អាស្រ័យហេតុនេះ ភាពយឺតយ៉ាវនៃការ តាំងចិត្ត និងការរៀបចំកិច្ចដំណើរការផ្ទេរមុខងារ និងធនធានទៅឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ក៏ជាចំណោទ មួយដែលពុំអាចជំរុញកិច្ចដំណើរការកំណែទម្រង់របស់យើងទៅមុខបានដែរ។

ខ្ញុំយល់ថា បញ្ហាសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ពុំគួរត្រូវបានយល់ថាជាចំណោទដែល យើងពុំអាចផ្ទេរមុខងារ និងធនធានសមស្របមួយចំនួនទៅឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិនោះទេ ព្រោះយើង ទាំងអស់គ្នាជាអ្នកទទួលខុសត្រូវក្នុងការផ្តល់សមត្ថភាពដល់រដ្ឋបាលទាំងនោះ។

ក្នុងខណៈដែលរចនាសម្ព័ន្ធ និងប្រព័ន្ធសំខាន់ៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំឡើង វិញ និងដាក់ឲ្យអនុវត្តជាបណ្តើរៗរួចហើយនោះ នេះជាពេលវេលាដ៏សមស្របមួយ ដែលយើងត្រូវចាប់ ផ្តើមគិតគូរអំពីការផ្ទេរមុខងារ និងធនធានទៅឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ទាំងនោះ មានលទ្ធភាពគ្រប់គ្រាន់ក្នុងការរៀបចំ និងគ្រប់គ្រងការផ្តល់សេវានានាដែលខ្លួនអាចធ្វើបាន ប្រកបដោយប្រសិទ្ធភាពជូនប្រជាពលរដ្ឋ តាមតម្រូវការដែលបានកំណត់នៅក្នុងផែនការអភិវឌ្ឍន៍របស់ខ្លួន

ក្រោមការទទួលខុសត្រូវយ៉ាងពេញលេញ និងមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

ជាការពិតណាស់ កិច្ចដំណើរការផ្ទេរមុខងារ និងធនធាន គឺជាកិច្ចការដ៏សាំញ៉ាំ និងរសើប តែជាកិច្ចការដែលយើងទាំងអស់គ្នាចាំបាច់ត្រូវតែអនុវត្ត ដោយមានការតាំងចិត្ត និងការសម្របសម្រួលជាមួយយុទ្ធសាស្រ្តតាមវិស័យនានាសម្រាប់ការលើកកម្ពស់ការផ្តល់សេវាសាធារណៈ។ យើងត្រូវបំពេញការងារនេះដោយប្រុងប្រយ័ត្ន និងដោយផ្អែកលើស្ថានភាពជាក់ស្តែងនៃសង្គម សេដ្ឋកិច្ច និងសមត្ថភាពធនធានមនុស្សរបស់យើង ជាមួយការរៀនសូត្របទពិសោធន៍ពីប្រទេសផ្សេងៗទៀត ទាំងនៅក្នុង និងនៅក្រៅតំបន់ ដើម្បីបង្ការកុំឲ្យមានការខុសឆ្គង និងត្រៀមលក្ខណៈបង្ការជាមុននូវបញ្ហាប្រឈម និងការគ្រប់គ្រងហានិភ័យនានា ដែលអាចលេចចេញពីដំណើរការផ្ទេរមុខងារ និងធនធាននេះឲ្យស្ថិតនៅក្នុងកម្រិតមួយដែលអាចគ្រប់គ្រង និងដោះស្រាយបាន។

ពាក់ព័ន្ធនឹងកិច្ចការនេះ អនុគណៈកម្មាធិការមុខងារ និងធនធាន និងលេខាធិការដ្ឋាន គ.ជ.អ.ប ដោយមានកិច្ចសហការជាមួយក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធសំខាន់ៗ បាន ធ្វើការសិក្សា និងរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីដំណើរការទូទៅនៃការផ្ទេរមុខងារ និងធនធានទៅឲ្យ រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងគោលបំណងកំណត់នូវគោលការណ៍សំខាន់ៗ និងកិច្ចដំណើរការទូទៅនៃការរៀបចំផ្ទេរមុខងារ និងធនធានទៅឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីជានាឲ្យកិច្ចដំណើរការផ្ទេរមុខងារ និងធនធាននេះប្រព្រឹត្តទៅនៅក្នុងលក្ខណៈជាប្រព័ន្ធ ជាជំហានៗ និងដោយប្រុងប្រយ័ត្ន។ ក្នុងកិច្ចប្រជុំរបស់យើងនាពេលព្រឹកនេះ យើងនឹងពិភាក្សា ផ្តល់យោបល់ និងឯកភាពលើសេចក្តីព្រាងអនុក្រឹត្យនេះ ដើម្បីដាក់ជូនរាជរដ្ឋាភិបាលពិនិត្យ និងសម្រេចនៅក្នុងត្រីមាសទី១នៃឆ្នាំ២០១២នេះ។

### ទីបី៖ ការពង្រឹងប្រព័ន្ធគណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

ច្បាប់រៀបចំអង្គការ និងកម្មវិធីជាតិបានតម្រូវឲ្យមានការផ្លាស់ប្តូរប្រព័ន្ធអភិបាលកិច្ចនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីឈានឆ្ពោះទៅរកប្រព័ន្ធអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យ។ ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានបង្កើតឡើងតាមរយៈការបោះឆ្នោតដោយសកល និងអសកល។ ក្រុមប្រឹក្សាទាំង នេះគឺជាអង្គភាពអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យ តំណាងឲ្យសម្លេង ឆន្ទៈ ផលប្រយោជន៍របស់ប្រជាពលរដ្ឋ និងត្រូវមានគណនេយ្យភាពជាបឋមចំពោះប្រជាពលរដ្ឋនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ដូច្នេះការពង្រឹងប្រព័ន្ធគណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសគណនេយ្យភាពចំពោះប្រជាពលរដ្ឋក្នុងមូលដ្ឋានរបស់ខ្លួន គឺជាចំណុចស្នូលនៃអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យ។

អាស្រ័យហេតុនេះ ក្នុងឆ្នាំ២០១២ ត្រូវបន្តការយកចិត្តទុកដាក់បន្ថែមទៀតទៅលើការរៀបចំ និងពង្រឹងការអនុវត្តនូវប្រព័ន្ធគណនេយ្យភាព រួមជាមួយនឹងការពង្រឹងសមត្ថភាព និងការយល់ដឹង ដល់រដ្ឋបាលថ្នាក់ក្រោមជាតិអំពីទស្សនទាន និងប្រព័ន្ធគ្រប់គ្រងក្រោមក្របខ័ណ្ឌនៃគោលការណ៍អភិបាល កិច្ចតាមបែបប្រជាធិបតេយ្យដែលជាល័ក្ខខ័ណ្ឌចាំបាច់សម្រាប់ប្រសិទ្ធភាពនៃការដឹកនាំ ការសម្រេចចិត្ត ការ

គ្រប់គ្រង និងការអភិវឌ្ឍន៍មូលដ្ឋានរបស់ខ្លួន។ ជាមួយគ្នានេះដែរ ក៏ត្រូវផ្តោតយកចិត្តទុកដាក់ផងដែរ លើការសិក្សា និងរៀបចំលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងការផ្តល់សិទ្ធិអំណាចដល់រដ្ឋបាលថ្នាក់ក្រោមជាតិលើការគ្រប់គ្រងបុគ្គលិក និងធនធានមនុស្សរបស់ខ្លួន និងគោលការណ៍ណែនាំបច្ចេកទេសនានាពាក់ព័ន្ធនឹងការពង្រឹងការប្រាស្រ័យទាក់ទងរវាងក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ ជាមួយប្រជាពលរដ្ឋតាមរយៈវេទិការសាធារណៈ ឬតាមមធ្យោបាយសមស្របផ្សេងទៀត។ល។

**ឯកឧត្តម លោកជំទាវ លោកស្រី អស់លោក!**

ខ្ញុំសង្ឃឹមថា បញ្ហាប្រឈមជាគន្លឹះមួយចំនួនខាងលើនេះ នឹងអាចដោះស្រាយបានមួយផ្នែកធំ តាមរយៈកិច្ចប្រជុំលើកទី៦របស់ គ.ជ.អ.ប នាឱកាសនេះ ដោយសារកិច្ចប្រជុំនេះ យើងនឹងផ្តោតទៅលើរបៀបវារៈសំខាន់ៗ ជាអាទិ៍៖

១. ការពិនិត្យ និងអនុម័តលើកំណត់ហេតុនៃកិច្ចប្រជុំលើកទី៥របស់ គ.ជ.អ.ប

២. របាយការណ៍ស្តីពីវឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាព និងថវិកាឆ្នាំ២០១១

៣. ការពិនិត្យ និងសម្រេចលើសេចក្តីព្រាងផែនការសកម្មភាព និងថវិកាឆ្នាំ២០១២

៤. ការពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យស្តីពីកិច្ចដំណើរការទូទៅនៃការផ្ទេរមុខងារ និងធនធានឲ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិ

៥. ការពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃមូលនិធិក្រុង ស្រុក

៦. បញ្ហាផ្សេងៗ

អាស្រ័យហេតុនេះ ខ្ញុំសង្ឃឹមថា ឯកឧត្តម លោកជំទាវ សមាជិក សមាជិកានៃ គ.ជ.អ.ប ឯកឧត្តម លោកជំទាវ លោកស្រី អស់លោកទាំងអស់ដែលមានវត្តមាននាឱកាសនេះនឹងចូលរួមពិនិត្យ ពិភាក្សា ផ្លាស់ប្តូរមតិយោបល់ និងផ្តល់ អនុសាសន៍ល្អៗយ៉ាងផុលផុសលើខ្លឹមសារនីមួយៗនៃសេចក្តីព្រាងឯកសារខាងលើនេះ។

នាឱកាសដ៏ថ្លៃថ្លានេះ ជាថ្មីម្តងទៀតក្នុងនាម គ.ជ.អ.ប និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមប្រសិទ្ធពរជ័យជូនឯកឧត្តម លោកជំទាវ លោកស្រី អស់លោកទាំងអស់ សូមទទួលបាននូវសុខភាពល្អ និងជោគជ័យថ្មីៗបន្ថែមទៀត និង សូមប្រកាសបើកកិច្ចប្រជុំលើកទី៦របស់ គ.ជ.អ.ប ចាប់ពីពេលនេះតទៅ។

**សូមអរគុណ!**